ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

**សូមគោរពជូន**
**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

**សម្តេចកិត្តិសង្គហបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសដ៏មហាប្រសើរប្រកបដោយក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាប្រកបដោយកក្តីភាព និងការគោរពដឹងគុណជានិច្ចចំពោះ **សម្តេចកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** ដែលបាននិងកំពុងដឹកនាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងនីតិរដ្ឋ ឈានទៅការរីកចម្រើនយ៉ាងឆាប់រហ័សនិងច្រើនឥតគណនាលើគ្រប់វិស័យទាំងអស់នៅកម្ពុជា និងសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជនដូចសព្វថ្ងៃ។

ក្នុងឱកាសប្រកបដោយសិរីសួស្តី នៃអំណរសាទរឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ពិសេសទេវតាឆ្នាំថ្មីព្រះនាម **កិមិរាទេវី** សូមយាងប្រោសប្រទានពរជ័យ បវរសួស្តី សិរីមង្គលគ្រប់ប្រការជូន **សម្តេចកិត្តិសង្គហបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តរួមចំណែកដឹកនាំរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យកាន់តែឈានឆ្ពោះទៅការរីកចម្រើន ភាពសម្បូរសប្បាយរុងរឿង និងសុភមង្គលរបស់ប្រជាជនកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចកិត្តិសង្គហបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** សមប្រកបនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ ចន្ទ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុន សុខា**

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh